

# តើអ្នកមានបញ្ហាជាមួយសេវាទូរស័ព្ទ ឬសេវាអ៊ីនធឺណិតរបស់អ្នកមែនទេ ?

## យើងអាចជួយបាន។

**tio.com.au**

1800 062 058

Telecommunications
Industry
Ombudsman



# យើងជួយដោះស្រាយបណ្តឹងតវ៉ាអំពីសេវាទូរស័ព្ទ ឬសេវាអ៊ីនធឺណិត។

## យើងគឺជាសេវាកម្មឯករាជ្យ និងឥតគិតថ្លៃ។ នោះមានន័យថាអ្នកមិនបាច់បង់ប្រាក់ ហើយយើងមិនកាន់ជើងខាងណាឡើយ។

Telecommunications Industry Ombudsman អាចជួយជាមួយ៖

- **កិច្ចសន្យា៖** តើអ្នកបានយល់ព្រមជាមួយនឹងអ្វីមួយដែលអ្នកមិនបានទទួលដែរឬទេ ?
- **វិក្កយបត្រ៖** តើអ្នកគិតថាវិក្កយបត្ររបស់អ្នកខុស ឬអ្នកកំពុងមានបញ្ហាក្នុងការបង់វាដែរឬទេ ?
- **កំហុស និងបញ្ហាលំបាកនៃសេវាកម្ម៖** តើសេវាទូរស័ព្ទ ឬសេវាអ៊ីនធឺណិតរបស់អ្នកមិនដើរមែនទេ ?
- **ការដាច់អ៊ីនធឺណិត៖** តើទូរស័ព្ទ ឬអ៊ីនធឺណិតរបស់អ្នកត្រូវបានកាត់ផ្តាច់មែនទេ ?
- **ការប្រមូលបំណុល៖** តើគេកំពុងស្នើឲ្យអ្នកសងបំណុលដែលមិនមែនជារបស់អ្នកមែនទេ ?
- **ការអនុវត្តការលក់៖** តើគេបានលក់គម្រោង ឬបរិក្ខារដែលអ្នកគ្មានលទ្ធភាពទិញឲ្យអ្នកមែនទេ ?

**Telecommunications Industry Ombudsman**

## របៀបដែលយើងធ្វើការជាមួយអ្នក និងក្រុមហ៊ុនផ្តល់សេវា

បើសិនជាអ្នក ឬបុគ្គលដែលអ្នកកំពុងទូរស័ព្ទជំនួស ប្រើប្រាស់ទូរស័ព្ទ ឬអ៊ីនធឺណិត យើងអាចជួយអ្នកបាន។ វាអាចជាសេវាកម្មមួយដែលត្រូវបានប្រើនៅផ្ទះ ឬអាជីវកម្មខ្នាតតូច។ នេះជារបៀបដែលវាដំណើរការ៖

1. អ្នកព្យាយាមដោះស្រាយបណ្តឹងតវ៉ាជាមួយក្រុមហ៊ុនផ្តល់សេវារបស់អ្នក។
2. បើសិនជាអ្នកមិនអាចដោះស្រាយបណ្តឹងតវ៉ាជាមួយក្រុមហ៊ុនផ្តល់សេវារបស់អ្នកបានទេ ចូរទូរស័ព្ទមកយើង។
3. យើងនឹងធ្វើការសម្រេចថាតើយើងអាចដោះស្រាយបណ្តឹងតវ៉ានេះបានឬអត់។
4. យើងធ្វើការជាមួយអ្នក និងក្រុមហ៊ុនផ្តល់សេវាដើម្បីដោះស្រាយបណ្តឹងតវ៉ា។
5. បើសិនជាអ្នក និងក្រុមហ៊ុនផ្តល់សេវាមិនឯកភាពគ្នាទេ មន្ត្រីស៊ើបអង្កេតពីការតវ៉ាអាចធ្វើការសម្រេចពីរបៀបដោះស្រាយបណ្តឹងតវ៉ានេះ។

## ការរកនរណាម្នាក់ឲ្យជួយអ្នក

អ្នកក៏អាចស្នើឲ្យអ្នកដទៃជួយប្តឹងតវ៉ាជំនួសអ្នក ឬអាជីវកម្មរបស់អ្នក ដូចជាមិត្តភក្តិ សមាជិកគ្រួសារ ឬទីប្រឹក្សាហិរញ្ញវត្ថុ។ ស្នើសុំទម្រង់ពាក្យផ្តល់សិទ្ធិអនុញ្ញាតរបស់យើងតាមទូរស័ព្ទ ឬស្វែងរកទម្រង់ទាំងនេះនៅលើគេហទំព័ររបស់យើង។

## ទាក់ទងមកយើង

អ្នកអាចប្តឹងតវ៉ាតាមរយៈគេហទំព័ររបស់យើងតាមអាសយដ្ឋាន **www.tio.com.au** ឬដោយទូរស័ព្ទទៅលេខ **1800 062 058**។

អ្នកអាចផ្ញើសំបុត្រតាមប្រៃសណីយមកកាន់ PO Box 276, Collins Street West, VIC 8007 ឬផ្ញើវាតាមទូរសារទៅលេខ 1800 630 614។

បើសិនជាអ្នកត្រូវការប្រើភាសាក្រៅពីភាសាអង់គ្លេស ចូរទូរស័ព្ទទៅសេវាកម្មបកប្រែអត្ថបទ និងបកប្រែផ្ទាល់មាត់តាមរយៈលេខ **131 450** ហើយពួកគេនឹងជួយឲ្យអ្នកនិយាយជាមួយយើង។ ពួកគេគឺជាសេវាកម្មឥតគិតថ្លៃ។

ការហៅទូរស័ព្ទទៅលេខខាងលើតាមទូរស័ព្ទចល័តអាចត្រូវបានគិតថ្លៃ។